**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងពង្រឹងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រដែលជួបការលំបាក ដើម្បីទទួលបានសេវាអប់រំប្រកបដោយសមធម៌ នៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅ៖

- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ
- កំណត់លក្ខខណ្ឌនិងនីតិវិធីសម្រាប់ការផ្តល់អាហារូបករណ៍។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសិស្សក្រីក្រដែលជួបការលំបាក នៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ តាមគ្រឹះស្ថានសិក្សាសាធារណៈ។

## ជំពូកទី២
## កម្រិតនិងលក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍

**មាត្រា៤.-**

អាហារូបករណ៍ត្រូវផ្តល់ជូនក្នុងមួយឆ្នាំសិក្សាដល់សិស្សក្រីក្រម្នាក់ៗ នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ តាមកម្រិតដូចខាងក្រោម៖

- បឋមសិក្សា : ២៤០ ០០០រៀល
- មធ្យមសិក្សាបឋមភូមិ : ២៤០ ០០០រៀល
- មធ្យមសិក្សាទុតិយភូមិ : ៣៦០ ០០០រៀល

ប្រាក់អាហារូបករណ៍សម្រាប់សិស្សម្នាក់ៗក្នុង១ឆ្នាំសិក្សា ត្រូវបើកផ្តល់ចំនួន៣(បី)លើក ស្របតាមឆ្នាំថវិកា។

**មាត្រា៥.-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦.-**

ការកំណត់ឈ្មោះសិស្សដែលត្រូវទទួលបានអាហារូបករណ៍ ត្រូវរៀបចំឡើងវិញមួយឆ្នាំម្តងដោយគណៈកម្មការជ្រើសរើសអាហារូបករណ៍របស់គ្រឹះស្ថានសិក្សា។

សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការជ្រើសរើសអាហារូបករណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រចាប់ពីថ្នាក់ទី៤ដល់ថ្នាក់ទី១២ ត្រូវអនុវត្តចាប់ពីឆ្នាំសិក្សា ២០១៤-២០១៥តទៅ។

ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី៣ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមស្ថានភាពហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៨ .-**

អនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ស្ដីពីការកំណត់ចំណាយដោយឡែក សម្រាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៃការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក សម្រាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com